# 소망의 여인들

## Prayer Calander

2024년 4월

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់



**ការអធិស្ឋានសម្រាប់ស្ត្រីនៅអាមេរិកខាងជើងនិងខាងត្បូង 2**

តើមានពេលប៉ុន្មានដងដែលអ្នកចំណាយពេលសម្លឹងមើលទៅព្រះយេស៊ូ?
តើមានគំនិតអ្វីកើតឡើងនៅពេលអ្នកឮអំពីព្រះនាមរបស់ព្រះយេស៊ូ? ព្រះនាមរបស់ព្រះយេស៊ូវគឺស្រស់សោភា ហើយល្អ ហើយគ្មានអ្វីអាចប្រៀបធៀបនឹងព្រះនាមរបស់ទ្រង់បានឡើយ ជានាមដែលខ្ពស់លើសអស់ទាំងនាម។
មានតែព្រះយេស៊ូវប៉ុណ្ណោះទេ ដែលអាចផ្តល់ឱ្យយើងនូវសន្តិភាពដ៏ពិតដែលអាចសម្រាលរាល់ទាំងបញ្ហា និងទុក្ខកង្វល់នៅពេលដ៏លំបាកបំផុតក្នុងជីវិតរបស់យើង ។
សូមឲ្យយើងចូលទៅបល្ល័ង្កនៃព្រះគុណរបស់ទ្រង់ដោយភាពក្លាហាន ដោយពឹងផ្អែកលើព្រះយេស៊ូវ ដែលទ្រង់នឹងជួយយើងក្នុងស្ថានភាពដ៏ទន់ជ្រាយ និងខ្សោយរបស់យើង។យៗ។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면 매주 월요일에 한국어 기도카드를 받으실 수 있습니다.

1. ឱព្រះវរបិតាអើយ
សូមជួយស្ត្រីវ័យចំណាស់នៅសាធារណរដ្ឋដូមីនីកែន ក្នុងការគាំទ្រ និងណែនាំស្ត្រីវ័យក្មេងនៅទីនោះអំពីរបៀបរស់នៅដែលប្រកបដោយប្រាជ្ញា និងពឹងផ្អែកទៅលើព្រះនាមទ្រង់។ (ទីតុស ២:៤-៥)

2. ព្រះជាអម្ចាស់ យើងសូមអធិស្ឋានសម្រាប់ព្រះពរក្នុងការផ្គត់ផ្គង់កម្លាំង នៅតែបន្តមានសម្រាប់អ្នកម្តាយនៅក្នុងប្រទេសប្រេស៊ីល ដែលមានកូនដែលមានពិការភាព ហើយត្រូវបានប្តីបោះបង់ចោលផងដែរ។ (ចោទិយកថា ៣១:៦)

3. ព្រះអម្ចាស់អើយ
សូមផ្តល់ការព្យាបាលដល់ស្ត្រីដែលត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺមហារីកនៅក្នុងប្រទេសប៉ារ៉ាហ្គាយ ដែលមិនបានទទួលការព្យាបាលត្រឹមត្រូវ ដោយសារការខ្វះធនធាននៅក្នុងប្រព័ន្ធថែទាំសុខភាពរបស់ប្រទេសនោះ។ (យេរេមា ១៧:១៤)

4. កូនសូមសរសើរព្រះនាមទ្រង់
ចំពោះការឆ្លើយតបរបស់អ្នកស្តាប់ដែលមានលទ្ធផលវិជ្ជមានចំពោះកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ដែលបានចាក់ផ្សាយពីរដងក្នុងមួយសប្តាហ៍នៅអ៊ុយរូហ្គាយ និងជារៀងរាល់ថ្ងៃនៅលើអ៊ីនធឺណេត និងប្រព័ន្ធផ្សព្វផ្សាយសង្គមនានាផងដែរ។ (ទំនុកតម្កើង ១០៥:១-២)

5. ព្រះវរបិតាអើយ យើងអធិស្ឋានសុំការការពារ ការព្យាបាល និងកន្លែងសុវត្ថិភាពសម្រាប់ស្ត្រី និងបុរសនៃ Bonaire ដែលជួបប្រទះអំពើហិង្សាក្នុងគ្រួសារ។ (ទំនុកតម្កើង ៩:៩-១០)

6. ព្រះអម្ចាស់អើយ
សូមដកភាពភ័យខ្លាចចេញពីក្នុងជីវិតរបស់ស្ត្រីនៅសហរដ្ឋអាមេរិក។ សូមឱ្យពួកគេទុកចិត្តលើទ្រង់ ហើយរៀនក្នុងការទទួលការសម្រាកនៅក្នុងទ្រង់សម្រាប់ការការពារ និងការផ្គត់ផ្គង់របស់ពួកគេផងដែរ។ (ទំនុកតម្កើង ៣៤:៨-១០)

7. ព្រះជាម្ចាស់អើយ
សូមអោយអស់អ្នកដែលទទួលបានប្រអប់ស្ពឹកគ័រ ដែលមានកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ដែលត្រូវបានផ្ញើរមកពីប្រទេសកាណាដាជុំវិញពិភពលោក បានស្គាល់ព្រះនាមទ្រង់ និងមានការផ្លាស់ប្តូរតាមរយៈទ្រង់ផងដែរ។ (២កូរិនថូស ៥:១៧)

8. បិតាអើយ សូមប្រទានប្រាជ្ញា និងភាពក្លាហានដល់ស្ត្រីនៅសាធារណរដ្ឋដូមីនីកែន ក៏ដូចជាស្វាមីរបស់ពួកគេ ដែលមានតួនាទីចិញ្ចឹមកូនដែលមានវ័យជំទង់។ (ចោទិយកថា ១១:១៩)

9. យើងសូមសរសើរព្រះនាមទ្រង់
ចំពោះក្រុមការងារស្ត្រីក្នុងក្តីសង្ឃឹមនៅប្រទេសប្រេស៊ីល និងក្រុមអ្នកស្ម័គ្រចិត្តសម្រាប់ឆន្ទៈ ការលះបង់ និងសេចក្តីស្រឡាញ់របស់ពួកគេចំពោះទ្រង់ និងព័ន្ធកិច្ចរបស់ទ្រង់។ (ភីលេម៉ូន ១:៤)

10. បិតាអើយ សូមប្រទានកម្លាំង និងប្រោសដួងចិត្តរបស់អ្នកម្តាយក្នុងប្រទេសប៉ារ៉ាហ្គាយ ដែលរងទុក្ខដោយសារកូនរបស់ពួកគេដែលមានការពាក់ព័ន្ធជាមួយគ្រឿងញៀន និងនៅក្នុងគុក។
សូមជួយកូនរបស់ពួកគេឱ្យរកឃើញសេរីភាពនៅក្នុងទ្រង់។ (កាឡាទី ៥:១)

11. ព្រះអង្គអើយ នៅក្នុងការបោះឆ្នោតឆ្នាំ ២០២៤ របស់អ៊ុយរូហ្គាយ សូមជួយអ្នកបោះឆ្នោតឱ្យជ្រើសរើស និងតែងតាំងអ្នកដឹកនាំដែលមានភាពយុត្តិធម៌ ស្មោះត្រង់ និងមានសេចក្តីមេត្តា ជាមនុស្សដែលខ្វល់ខ្វាយជាមួយតម្រូវការរបស់ប្រជាជន។ (រ៉ូម ១៣:៣-៤)

12. ព្រះអម្ចាស់អើយ
ទូលបង្គំអធិស្ឋានសូមឲ្យអស់អ្នកដែលស្តាប់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ដែលផ្សាយពី Bonaire នឹងទទួលយកព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ពួកគេ ហើយមានសេចក្តីអំណរនៅក្នុងទ្រង់ផងដែរ។ (ទំនុកតម្កើង ៧៣:២៨)

**TWR Korea 북방선교방송**
서울특별시 관악구 양녕로 15, 월드빌딩 6층
전화 (02)886-5671 / 이메일 phkorea@twrk.or.kr




13. ព្រះវរបិតា ទ្រង់គឺជាព្រះនៃទំនាក់ទំនង។ សូមជួយស្ត្រីវ័យក្មេងរបស់យើងនៅសហរដ្ឋអាមេរិកឱ្យពួកគេមានបំណងចិត្ត និងរៀនពីរបៀបដែលអាចមានទំនាក់ទំនងដែលផ្តល់ជីវិតដ៏មានន័យ និងស្របតាមបំណងព្រះហឫទ័យរបស់ទ្រង់។ (១កូរិនថូស ១៣:៤-៧)

14. សរសើរតម្កើងដល់ព្រះជាម្ចាស់ចំពោះកម្មវិធីថ្មីដែល TWR នៅ Canada កំពុងចាប់ដៃគូជាមួយកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ក្នុងឆ្នាំ២០២៤ ដើម្បីចែករំលែកក្តីសង្ឃឹមរបស់ព្រះយេស៊ូវជាមួយស្ត្រីនៅជុំវិញពិភពលោក។ (១កូរិនថូស ៣:៩)

15. បិតាអើយ សូមជួយស្ត្រីនៅសាធារណរដ្ឋដូមីនីកែន ឱ្យចេះគ្រប់គ្រងកាលវិភាគការងាររបស់ពួកគេដោយជោគជ័យជាមួយអ្វីដែលល្អបំផុតសម្រាប់ទំនាក់ទំនងក្នុងគ្រួសារ និងអាពាហ៍ពិពាហ៍របស់ពួកគេ។ (ទំនុកតម្កើង ៩០:១៧)

16. ព្រះនៃសេចក្តីមេត្តាករុណា សូមជួយសង្គ្រោះក្មេងស្រី និងស្ត្រីនៅប្រេស៊ីលដែលរងគ្រោះពីការជួញដូរ។ សូមនាំមកនូវការព្យាបាល និងជីវិតថ្មីដល់ពួកគេ។ (យេរេមា ៣៣:៦)

17. ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមឲ្យស្ត្រីជាំវ៉ាហ្កាយមានសិទ្ធិទទួលបានការអប់រំស្មើៗគ្នា ហើយសូមអោយរនាំងនៃការរារាំងឧបសគ្គចំពោះការអភិវឌ្ឍន៍ខ្លួន ការសិក្សាត្រូវបានដកចេញ។ (កាឡាទី ៣:២៨)

18. ព្រះអម្ចាស់អើយ សូមឱ្យស្ត្រីនៅអ៊ុយរូហ្គាយបានស្វែងរកសន្តិភាពនៅក្នុងព្រះយេស៊ូវហើយដឹងពីតម្លៃដែលទ្រង់បានលះបង់សម្រាប់ពួកគេ។ សូមរំដោះពួកគេពីគ្រឿងញៀន និងពីអស់អ្នកដែលចង់ធ្វើបាបពួកគេ។ (យ៉ូហាន ១៤:២៧)

19. ព្រះអង្គអើយ យើងអធិស្ឋានសូមអោយទ្រង់បានពង្រឹងទំនាក់ទំនងអាពាហ៍ពិពាហ៍នៅ Bonaire និងការពារពួកគេពីផែនការដ៏អាក្រក់របស់សាតាំង។ សូមផ្តល់ឱ្យគូស្នេហ៍ទាំងនេះនូវព្រះគុណ និងការដឹកនាំដែលមកពីទ្រង់។ (១កូរិនថូស ១៦:១៤)

20. ព្រះវរបិតានៃជីវិតអស់កល្បអើយ សូមទ្រង់ជួយស្ត្រីនៅសាធារណរដ្ឋដូមីនីកែន ឲ្យជឿទុកចិត្តថាទ្រង់នឹងជួយពួកគេឱ្យបំពេញតួនាទីជាភរិយាដ៏ល្អបាន។ (សុភាសិត ៣:៥-៦)

21. បិតាអើយ សូមប្រទានសិទ្ធិក្នុងការទទួលបានការថែទាំសុខភាពដែលប្រកបដោយគុណភាពសម្រាប់ស្ត្រីប្រេស៊ីលដែលមានភាពក្រីក្រក៏ដូចជាអស់អ្នកដែលរស់នៅក្នុងតំបន់ដែលមានសេវាវេជ្ជសាស្ត្រមានកម្រិតផងដែរ។ (ទំនុកតម្កើង ១៤០:១២)

22. ព្រះបិតាអើយ សូមផ្តល់ការការពារ និងសុវត្ថិភាពសម្រាប់ស្ត្រីនៅជាំវ៉ាហ្កាយ ដែលប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារ ដែកផ្អែកលើយេនឌ័រ។ សូមជួយពួកគេអោយស្វែងរកទីជម្រក និងការគាំទ្រដើម្បីជម្នះលើការលំបាកទាំងនេះផងដែរ។ (ទំនុកតម្កើង ១០:១៧-១៨)

23. ព្រះអម្ចាស់អើយ ទ្រង់មានព្រះបន្ទូលថា ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ។ នៅអ៊ុយរូហ្គាយ កុមារ ២១% កើតមកក្នុងភាពក្រីក្រ។ យើងអធិស្ឋានសូមសេចក្តីមេត្តាករុណាដល់កូនៗរបស់យើង សូមឱ្យពួកគេបានស្គាល់ក្តីស្រឡាញ់របស់អ្នកទ្រង់។ (ម៉ាថាយ ១៩:១៤)

24. ព្រះអង្គអើយ យើងអធិស្ឋានសុំឱ្យក្មេងស្រីនៅ Bonaire ដឹងពីតម្លៃពិតរបស់ពួកគេនៅក្នុងទ្រង់ ហើយកុំអោយពួកគេបានស្វែងរកទំនាក់ទំនងដែលមិនត្រឹមត្រូវដើមប្បីការសប្បាយ នោះឡើយ។ (សុភាសិត ១៣:២០)

25. ព្រះអម្ចាស់អើយ សូមអោយស្ត្រីនៅសាធារណរដ្ឋដូមីនីកែន ថ្វាយដួងចិត្តរបស់ពួកគេដល់ទ្រង់ ដោយស្វែងរកសេចក្តីសង្គ្រោះដែលមានក្នុងទ្រង់។ សូមពង្រឹងពួកគេឱ្យរក្សាភាពស្មោះត្រង់របស់គេចំពោះទ្រង់។ (កិច្ចការ ៤:១២)

26. បិតាអើយ សូមជួយស្ត្រីប្រេស៊ីលដែលជួបប្រទះការរំលោភបំពាន និងអំពើហិង្សាក្នុងគ្រួសារ អោយពួកគេបានផ្តាច់ចេញពីទំនាក់ទំនង និងរំលោភបំពានរបស់ពួកគេ ហើយស្វែងរកសុវត្ថិភាព និងការការពារនៅក្នុងទ្រង់។ (ទំនុកតម្កើង ៩:៩)

27. បិតាអើយ សូមអោយអ្នកម្តាយម្តាយដែលនៅលីវនៅប្រទេសជាំវ៉ាហ្កាយ ដែលចិញ្ចឹមកូនតែម្នាក់ឯង និងផ្តល់អ្វីៗគ្រប់យ៉ាងសម្រាប់គ្រួសាររបស់ពួកគេ បានស្វែងរកការគាំទ្រ និងធនធានដែលពួកគេត្រូវការផងដែរ។ (ម៉ាថាយ ៦:៣១-៣២)

28. ព្រះអម្ចាស់អើយ សូមផ្តល់ការងារសម្រាប់ជនចំណាកស្រុករាប់ពាន់នាក់ ដែលមកប្រទេសអ៊ុយរូហ្គាយ ដើម្បីជីវិតដែលប្រសើរជាងមុន ប៉ុន្តែត្រូវបញ្ចប់ដោយអំពើពេស្យាចារ។ សូមមានព្រះទ័យមេត្តាដល់ស្ត្រី និងក្មេងស្រីទាំងនេះ បិតាអើយ។ (ភីលីព ៤:១៩)

29. ព្រះជាអម្ចាស់ ដោយសារមានភាពចម្រុះជាច្រើននៅក្នុង Bonaire យើងអធិស្ឋានថាពួកគេនឹងមានការគោរពគ្នាទៅវិញទៅមក ដើម្បីអោយប្រជាជនអាចធ្វើការជាមួយគ្នាដើម្បីសេចក្តីសុខរបស់ប្រទេសរបស់ពួកគេផងដែរ។ (ភីលីព ២:៤-៥)

30. ព្រះអម្ចាស់អើយ សូមនាំមកនូវការព្យាបាលដល់ស្ត្រីនៅសាធារណរដ្ឋដូមីនីកែន ដែលត្រូវបានរំលោភបំពាន។ សូមផ្តល់ឱ្យពួកគេនូវភាពក្លាហានដើម្បីស្វែងរកជំនួយដែលពួកគេត្រូវការដើម្បីយកឈ្នះ និងបន្តដំណើរជីវិតរបស់ពួកគេផងដែរ។ (ទំនុកតម្កើង ១៤៧:៣)

**후원안내**

**국민은행 851-01-0003-724 북방선교방송**

**최초 입금 후 사무실로 연락주시기 바랍니다.**